ប្រសិនបើយើងសិក្សាទៅលើប្រវត្តិសាស្ត្រនៃរបបរាជានិយមចិនបុរាណ នឹងរកឃើញអំពើឃោរឃៅផ្តាច់ការ ដែលបណ្តាលឲ្យមានការដួលរលំជាបន្តបន្ទាប់នូវបណ្តារាជវង្សដូចជាច្រើនរួចមកហើយ។

បើទោះបីជាបានឆ្លងកាត់នូវសង្គ្រាមថ្មីក ច្បាប់តឹងរឹងហ្មត់ចត់ និងប្រព័ន្ធក្តាប់អំណាចដ៏រឹងមាំច្រើនជំនាន់ក្តី ក៏ប្រទេសចិនមានយុគកាលសម័យប្តូររាជមិនអស់មិនហើយ។

ជាមួយគ្នានោះនៅក្នុងសង្គមបុរាណមួយដែលលម្អៀង និយមវាយតម្លៃខាងស្រីទាប អ្នកសរសេរប្រវត្តិសាស្ត្រនិយមដាក់ការស្តីបន្ទោសអំពីមូលហេតុនៃដួលរលំទៅនៃរាជវង្សទាំងប៉ុន្មាននោះដោយដាក់កំហុសទៅលើស្ត្រីជាន់ខ្ពស់ ដែលពាក់ព័ន្ធជិតដិតនឹងរាជវង្សានុវង្ស ព្រះមហាក្សត្រ។ល។

ដំណើរលើរឿងបិសាចកញ្ជ្រោងនេះ កើតឡើងពាក់ព័ន្ធអំពីស្ត្រីដ៏ក្មេងពោរពេញទៅដោយសម្រស់ម្នាក់ឈ្មោះតាជី DaJi ដែលគេអធិប្បាយថាមានប្រវត្តិជួរជាតិ អាក្រក់ឃោរឃៅបំផុតមិនធ្លាប់មាននៅក្នុងបណ្តាប្រវត្តិសាស្ត្រយូរលង់នានារបស់ចិន។

រឿងព្រេងអំពីកញ្ជ្រោងកន្ទុយ៩ ដែលត្រូវបានគេស្គាល់ថា ជាប្រលោមលោកនិទានបុរាណផ្នែកមនោសញ្ចេតនាដ៏ពេញនិយមបំផុតនេះបានពណ៌នាតាជីថា ជាការចាប់កំណើតមកដើម្បីតែនឹងផ្តួលរំលំចោលរាជវង្សស្តេចចូវ។

ពីដំបូងតាជី គឺជាកូនស្រីពៅនៅក្នុងចំណោមកូនស្រីពីរនាក់របស់មេទ័ពត្រកូលស៊ូនៅក្នុងរាជវង្សចូវ។ ពេលដែលនាងទើបតែកើតមកភ្លាម ស្រាប់តែមេឃបង្អើតប្រផ្នូល មានភ្លៀងធ្លាក់ប្រាំពីរថ្ងៃប្រាំពីរយប់ ប្រទេសចិនទាំងមូលមិនបានស្គាល់ពន្លឺព្រះអាទិត្យឡើយ។

ម្តាយរបស់នាងបានហៅហោរាមកទស្សន៍ទាយ។ ហោរានោះបានប្រាប់ទៅកាន់ម្តាយឪពុកនាងថា កូនស្រីនេះមិនអាចទុកបានទេ ពីព្រោះនៅពេលនាងធំឡើង នឹងធ្វើឲ្យរលាយរាជវង្សចូវ
។

ដោយសារតែករណីនេះឪពុកនាងក៏ត្រៀមនឹងសម្លាប់នាងចោលភ្លាមៗតែម្តង ដោយសារតែចិត្តមានស្វាមីភក្តិចំពោះរាជវាំងក៏ប៉ុន្តែម្តាយនាងបានអង្វរសុំឪពុកនាងថា សូមតែបានឃើញមុខកូនស្រីពៅដល់ធំ សន្យាមិនបណ្តោយមានចេញពីផ្ទះជារៀងរហូត សូម្បីតែរៀបការប្តី។

ម្ល៉ោះហើយឪពុករបស់នាងបានដាក់លក្ខខណ្ឌតឹងរឹង មិនឲ្យនរណាម្នាក់បង្រៀនអក្សរដល់តាជី ឬសូម្បីតែនិយាយជាមួយនាងច្រើន។

នាងត្រូវបណ្ដោយឱ្យធំឡើងក្នុងសភាពរស់តែឯកឯងនាបន្ទប់ដាច់ឆ្ងាយពីគេមួយក្នុងសួនសម្ងាត់ក្បែរព្រៃ។

ទោះបីយ៉ាងណាព្រហ្មលិខិតបានកំណត់រួចមកហើយ។

នៅក្នុងការសរសេរទុក គឺគេកត់ត្រាថា បងស្រីរបស់នាងដែលតែងលបទៅជួបតាជីដើម្បីលេងកម្សាន្តជាមួយគ្នាតែងត្រូវតាជីហៅឱ្យបង្រៀនអក្សរ បង្រៀនកំណាព្យ បង្រៀនភ្លេងលាក់ពីឪពុក។ នៅពេលទំនេរទៀតសោត តាជីចូលចិត្តទៅលេងជាមួយសត្វព្រៃនានាជាច្រើន។

សម័យកាលនោះមានកញ្ជ្រោងពណ៌ប្រាក់មួយ ដែលត្រូវបានគេសន្មតថា បានរស់រានមានជីវិតជាងមួយពាន់ឆ្នាំមកហើយ ដោយចេះតាំងសិល្បសន្ស៊ំបានវេទមន្តខ្លាំងពូកែ អាចមានសមត្ថភាពប្រែក្រឡា អាចអន្ទងវិញ្ញាណព្រមទាំងអាចធ្វើអ្វីៗជាច្រើនទៀត។

មានការតំណាលថា អាទិទេពណ្វ៉ាដែល ក្នុងសម័យនោះមានតួនាទីតាមដានពីឋានសួគ៌អំពីពពួកស្តេចពុករលួយទាំងឡាយនៅលើផែនដី បានស្វែងរកកញ្ជ្រោងពណ៌ប្រាក់ដែលមានកន្ទុយប្រាំបួននោះ ហើយបានបង្គាប់ប្រាប់ថា ចូរឯងរកគ្រប់វិធីទៅកាន់រាជវង្សចូវដ៏ពុករលួយប្រើវេទមន្តនិងល្បិចដែលឯងមានធ្វើយ៉ាងណាឲ្យប្រជាជនងើបឡើងដោយកំហឹងនិងផ្តួលរំលំស្តេចចូវចោល។ ទណ្ឌកម្មរបស់ព្រះណ្វ៉ានេះលើស្តេចចូវក៏ព្រោះដោយសារតែចរិតរបស់ព្រះរាជាអង្គនេះ ដែលមិនអាចគ្រប់គ្រងប្រទេសជាតិបានល្អ សោយសាច់ឆៅ ល្មោភស្រា មានជំងឺកាមរោគច្រើន ថែមទាំងមានស្រីស្នំអនាចាររាប់មិនអស់។

នៅក្នុងសម័យកាលនោះ ស្តេចចូវមានវ័យជាងហុកសិបឆ្នាំទៅហើយដែលតាជីទើបមានវ័យដប់ប្រាំមួយឆ្នាំតែប៉ុណ្ណោះ។ ស្តេចចូវបានមានភរិយា ព្រមទាំងស្រីស្នំរាប់ពាន់នាក់។ ជាមួយបញ្ញារបស់ខ្លួន ព្រះណ្វ៉ាបានសន្យាជាមួយកញ្ជ្រោងថា នឹងប្រគល់ជីវិតអមតៈឱ្យ ប្រសិនអាចធ្វើឱ្យនគរនេះដួល ដោះដូររាជវង្សបាន។

កញ្ជ្រោងកន្ទុយ៩ បានសម្រេចចិត្តស្វះស្វែងរកមនុស្សស្រីមកពីត្រកូលអភិជនណាម្នាក់ដែលអាចចូលទៅនៅជិតក្បែរស្តេចចូវបាន។ ទីបំផុតក៏បានរកឃើញតាជីដែលជាកូនស្រីពៅរស់លាក់លៀម នៅក្នុងបន្ទប់សម្ងាត់មួយនៃត្រកូលអភិជនឈ្មោះថាស៊ូ ថាពិតជាស្រស់ស្អាតពិបាករកបានលើលោក។

ឈ្មោះពេញរបស់នាងត្រូវបានគេហៅតតាមគ្នាថាស៊ូតាជី។

នៅឆ្នាំ១០៤០ រាជវង្សចូវបានបន្តរើសស្រីស្នំក្មេងៗវ័យពី១២ទៅ១៦ឆ្នាំចូលវាំងជាបន្តទៀត។ បានន័យថារាល់បីឆ្នាំម្តង ស្រីក្រមុំដែលទើបនឹងធំឡើង ត្រូវបានស្តេចចូវតម្រូវហៅចូលមកក្នុងវាំង បង្ហាញសម្រស់។

ជាមួយព្រះជន្មហុកសិបវស្សាទៅហើយក្តី ស្តេចចូវដែលបានគ្រងរាជ្យអស់រយៈពេលជាងសែសិបឆ្នាំមកហើយនោះ បានបំភ្លេចអតីតកាល ដែលកាលពីដើមឡើយទ្រង់ត្រូវបានគេស្គាល់ថាជាកំពូលសឹកសង្គ្រាមខ្លាំងពូកែ បែរមកជាល្មោភសោយសុខរឿងតណ្ហានិង តូរ្យតន្ត្រីទៅវិញ ។

នៅក្រោមរជ្ជកាលរបស់ព្រះអង្គ ស្តេចចូវបានប្រែក្លាយនគរស្ហាងទៅជាជារដ្ឋដ៏មានអំណាច និងមានវិបុលភាព ប៉ុន្តែកេរ្តិ៍ឈ្មោះដ៏អាស្រូវគឺការរស់នៅជាមួយនឹងរឿងកាមតណ្ហាជាច្រើន ហួសហេតុរហូតមានអ្នកខ្លះសរសេរថាព្រះអង្គមានជំងឺកាមរោគ និងជំងឺវង្វេងវង្វាន់មាស់។

ទៅការកេណ្ឌស្ត្រីក្មេងៗស្អាតៗមកពីគ្រួសារដែលមានយសស័ក្តិ មានអំណាចចូលក្នុងវាំង គឺជាអ្វីៗដែលធ្វើឲ្យស្ថានការណ៍ទាំងឡាយកាន់តែអាក្រក់ឡើងៗសម្រាប់រាជនគរវេលានេះ ព្រោះថាគ្មាននរណាដឹងទេ ថាថ្ងៃនោះហេតុអ្វីបានជា ស៊ូតាជី ដែលឪពុកនាងក៏មិនដែលជួបមុខនាងផង បែរជាលេចមុខបាននៅក្នុងចំណោមស្រីស្នំថ្មីដែលត្រូវចូលខ្លួនទៅថ្វាយស្តេចជ្រើស។

តាមពិតការសរសេរខ្លះបានរៀបរាប់ថា ដោយសារតែជីនិយមរត់លេងជាមួយសត្វនៅពេលយប់ជ្រៅ ដូច្នេះហើយកញ្ជ្រោងកន្ទុយ៩ បានមានឱកាសក្នុងការហូតព្រលឹងសម្លាប់នាងចោល ហើយឆ្លងនៅក្នុងរូបរបស់នាង ព្រមទាំងធ្វើដំណើរចូលទៅក្នុងព្រះបរមរាជវាំង ដាក់ខ្លួនជាស្រីបម្រើសម្រាប់ព្រះរាជា។

ព្រះរាជាចូវដែលបានធុញទ្រាន់ជាខ្លាំងជាមួយស្រីស្អាតទាំងឡាយ ប៉ុន្តែនៅពេលដែលបានជួបតាជី គឺចាប់ផ្តើមលង់ស្នេហ៍នាងយ៉ាងលើសលប់ ដូច្នេះហើយមធ្យោបាយរបស់សត្វកញ្ជ្រោងកន្ទុយប្រាក់នៅក្នុងការបានចូលទៅកន្លែងខ្ពស់ហួសគេក្នុងរាជវាំងស្ហាងបានសម្រេចមួយជំហានធំ។

ព្រះអង្គវ័យចំណាស់និងតាជី បានក្លាយទៅជាគូស្នេហ៍ស្អិតបេះមិនចេញ ក្រោយពេលបានឃើញគ្នាដ៏ខ្លីហើយព្រះអង្គបានសព្វព្រះរាជហឫទ័យចំពោះនាង បំភ្លេចចោលអស់មហេសីព្រះស្នំទាំងពួងសូន្យ។

តាជីបានកាត់ចោលនូវរាល់មធ្យោបាយជ្រើសស្រីស្នំថ្មីចូលក្នុងវាំង ព្រមទាំងមិនបានអនុញ្ញាតទ្រង់ទៅជួបនារីដទៃណាក្តីដែលទ្រង់ធ្លាប់សព្វព្រះរាជហឫទ័យជាខ្លាំងក៏ដោយ។

នេះដោយសារតាជីមានវេទមន្តមិនឱ្យស្តេចណាយចិត្តចេញបាន។

ដោយសារនាងចូលចិត្តសត្វ ដូច្នេះព្រះរាជាបានសាងសង់សួនសត្វមួយឈ្មោះថា សាដូជី ជាការប្រទានដល់នាង ជាមួយនឹងការប្រមូលផ្តុំនៃពពួកអម្បូរសត្វស្លាប សត្វចម្លែក និងសត្វកម្រនានាក្នុងលោក។

តាជីតែងពង្វក់វាជាសម្រាប់ឲ្យកំដរនាងចូលរាំច្រៀងភ្លេង តាមទម្លាប់រស់នៅស្ងប់ស្ងាត់របស់នាង ព្រមទាំងបានបញ្ជាឲ្យអ្នកសិល្បៈ ទំនុកភ្លេងបង្កើតក្បាច់រាំស្រើបស្រាលជាច្រើនបែបសម្រាប់ផ្គាប់ចិត្តស្តេចចូវផងដែរ។

ដោយសារដូច្នោះ ស្តេចចូវចាប់ផ្តើមចំណាយពេលវេលាទាំងអស់ជាមួយតាជីចោលរាជកិច្ច។ រឿងដ៏សំខាន់មួយ គឺតាជី អាចបញ្ជាឲ្យអ្នកណាស្លាប់ ឬរស់បានដោយក្រោមរាជវង្សរបស់ស្តេចចូវមិនមានអ្នកណាអាចជាដៃគូតវ៉ាជាមួយនាងឡើយ។

ចុងក្រោយនាងបានសម្លាប់ព្រះមហេសី ដោយចោទព្រះមហេសីថាឆ្កួតនិងបានប្រាប់ស្តេចចូវថា នេះជារឿងជោគជតាកម្មពីជាតិមុនមក។

រឿងនេះបានធ្វើឲ្យមន្ត្រីទាំងអស់មួម៉ៅក្តៅក្រហាយជាខ្លាំង។

ពួកគេបានបញ្ចេញប្រតិកម្មប្រឆាំងពេញទំហឹងចំពោះអំណាចនិងភាពឆ្កួតលីលារបស់នាងកញ្ជ្រោងហើយមនុស្សទូទាំងនគរបានហៅនាងថា ជាបិសាចកញ្ជ្រោង។

សម័យថ្ងៃមួយ នាងបានទាមទារឱ្យមានកម្មវិធីពិធីរាំសម្រាតកាយ។ ស្តេចចូវកាន់តែងប់ងល់នឹងរឿងលើគ្រែលែងសមជាអ្នកគ្រងរាជ្យ។ ជាញឹកញាប់នៅក្នុងចំណោមនោះ មានព្រះរាជពិធីរាំសម្រាតដែលប្រមូលភ្ញៀវមកចូលរួមច្រើនឡើងៗ ចុងក្រោយក្លាយជាកម្មវិធីមួយមានការជំទាស់ពីមន្ត្រីនានារហូតត្រូវបញ្ឈប់បណ្តោះអាសន្ន។

នេះជាសញ្ញាថា នគរទាំងមូលបានដាក់ការប្រឆាំងនិងតំណែងដ៏ស្និទ្ធស្នាលរបស់នាងជាមួយស្តេចចូវ មិនទទួលយកតាជី ជាស្ត្រីកំពូលដូចចិត្តស្តេចចូវចង់បាននោះទេ។

ដោយសាររឿងនេះ តាជីកើតគំនិតវាយបក។ ជារៀងរាល់ថ្ងៃ នាងកញ្ជ្រោងមិនដែលផ្តល់ស្នាមញញឹមទៅកាន់ព្រះរាជានោះទេ ធ្វើឱ្យស្តេចចូវកើតទុក្ខខ្វល់ខ្វាយជាពន់ពេកណាស់។

ចុងក្រោយនាងកាន់តែមិននិយាយស្ដីមិនស្ដាប់ភ្លេង មិនឆីអាហារ។ ស្ដេចចូវហេតុចង់ផ្គាប់ឱ្យស្រីសប្បាយចិត្តក៏បញ្ជាឲ្យមានការជីកស្រះដ៏ធំមួយចាក់ស្រាពេញផ្ទៃស្រះ ដែលគេឲ្យឈ្មោះក្នុងប្រវត្តិសាស្ត្រចិនថា ព្រៃសាច់និងស្រះស្រា។ ព្រៃនោះនៅព័ទ្ធជុំវិញស្រះដែលផ្ទុកទៅដោយជាតិស្រា មានព្យួរសាច់នៅគ្រប់ដើមឈើនិងអនុញ្ញាតឲ្យភ្ញៀវទាំងអស់រត់លេងពាសពេញព្រៃនោះក្នុងរូបភាពអាក្រាតកាយសប្បាយក្អាកក្អាយរួមភេទគ្នាជាក្រុមយ៉ាងអនាចារ។ មនុស្សជាងដល់ទៅបីពាន់នាក់ត្រូវបានស្ដេចបញ្ជាឱ្យមកចូលរួមជាកំហិត។

អ្វីទាំងនេះគឺគ្រាន់តែស្ដេចចូវមានបំណងប៉ងប្រាថ្នាឱ្យតាជីញញឹមតែប៉ុណ្ណោះ ព្រោះអ្វីដែលនាងសប្បាយចិត្តបាន គឺមានតែពេលបានធ្វើទារុណកម្មមនុស្ស ឬបានធ្វើអ្វីៗរន្ធត់ៗចម្លែកៗ។

ករណីព្រៃសាច់ស្រះអាកុលនិងមនុស្សស្រោតជាងបីពាន់នាក់នេះ ស្ដេចចូវសង្ឃឹមថា នឹងធ្វើឲ្យតាជីបានមើលនិងរំភើបរីករាយជាខ្លាំង ព្រោះសារជាតិកញ្ជ្រោងបិសាចពិតជាអាចញញឹមសើចលេងសប្បាយបាន តែនៅពេលដែលឃើញរឿងអាក្រក់អាក្រីកើតឡើង ឬទារុណកម្ម

សាហាវៗ កើតមានឡើងនៅចំពោះមុខនាង។

មានកំណាព្យចាស់មួយបានសរសេរថា ព្រោះតែស្ដេចកំឡៅចង់ឃើញស្នាមញញឹមកញ្ជ្រោង មនុស្សជាច្រើនត្រូវសម្លាប់ លះបង់អស់សូម្បីអំណាច រួមទាំងតាជីអាចបញ្ជារាល់ការសម្លាប់មនុស្សនិងសាហាវឡើងៗ ដូចយ៉ាងនៅរាត្រីនៃការប្រជុំមនុស្សអាក្រាតជាងបីពាន់នាក់នោះ មានស្រីស្នំថ្នាក់ទីមួយម្នាក់ ដែលមកពីគ្រួសារព្រះអង្គម្ចាស់ជូ ហើយក្រោយមកត្រូវបានស្ដេចចូវសព្វព្រះទ័យលើនាងខ្លាំងតែងតាំងជាស្នំឯក។

ដោយជាស្ត្រីរម្យទម ស្នំឯកជូមិនអាចទ្រាំទ្រនឹងការប្រមាថមើលងាយដែលបង្ខំឲ្យគ្រប់គ្នាអាក្រាតរត់ពាសពេញព្រៃនោះ នាងបានសុំតវ៉ាជាមួយស្ដេចថា មិនអាចចូលរួមជាមួយល្បែងនេះ។

គ្រានោះស្ដេចចូវ មិនដឹងត្រូវធ្វើយ៉ាងណាឡើយ ប៉ុន្តែតាជីបានផ្ទុះកំហឹងហើយនិយាយថា នេះគឺជាការប្រមាថមាក់ងាយបញ្ជាស្ដេច ដូច្នេះស្ដេចចូវបានអង្គុយស្ញៀមស្ងឹងមើលតាជីបញ្ជាអោយនាម៉ឺនសម្លាប់ស្នំឯកជូ ព្រមទាំងកោះហៅទាំងឪពុករបស់នាងនាំមកផ្ដន្ទាទោសដោយអាំងសាច់ព្យួរ។

សូម្បីតែអ្នកណាដែលហ៊ានប្រកែកនឹងការប្រទានសាច់មនុស្សនេះក៏នឹងត្រូវទទួលទោសដល់ជីវិតដែរ ព្រោះតាជីចង់ឱ្យពួកគេរស់នៅរបៀបជាសត្វធាតុ ដែលនាងយល់ថាល្អ។

ភាពល្បីល្បាញអំពីអំពើកាចសាហាវរបស់តាជីត្រូវបាននិយាយ ល្បីរន្ទឺទៅដល់ចុងកាត់មាត់ញក ហើយអ្នកតែងកំណាព្យកាព្យឃ្លោងគ្រប់រូប ថែមទាំងបានបន្ថែមនូវទម្ងន់ទោសដល់នាងដោយនិយាយថា ជីវិតរបស់ស៊ូតាជី មិនអាចសើចរីករាយបានទេបើគ្មានឈាមស្រក់។

ជារៀងរាល់ថ្ងៃ នាងបានធ្វើទារុណកម្មមនុស្សព្រោះមានកំហុសតិចតួចឬសូម្បីតែគ្មានកំហុសព្រោះនាងចង់ឮសំឡេងស្រែករន្ធត់ ក្នុងទុក្ខវេទនារបស់មនុស្សនៅពេលទទួលរងទោសទណ្ឌតែប៉ុណ្ណោះ។

នាងធ្លាប់បញ្ជាឲ្យគេកាប់ជើងកសិករម្នាក់ចោលដោយគ្រាន់តែឆ្ងល់ថាហេតុអ្វីកសិករនោះគ្មានស្បែកជើងប៉ុន្តែអាចដើរទៅលើផ្ទៃទឹកកករងាបាន។

ក្រៅពីនោះនាងក៏បានឲ្យគេវះពោះស្ត្រីមានផ្ទៃពោះម្នាក់ដើម្បីឲ្យនាងបានឃើញថានៅក្នុងមានអ្វីខ្លះ។

ដោយសារតែអំពើសាហាវឃោរឃៅទារុណកម្មដោយអំណាចផ្តាច់ការរបស់នាង ព្រមទាំងភាពឆ្កួតលីលារបស់ស្តេចចូវ ដែលស្រវឹងទាំងព្រឹកទាំងល្ងាច ដំណឹងនេះលេចឮដល់បុរសវេទមន្តអាថ៌កំបាំងវ័យ៧២ឆ្នាំព្រះនាម លោកតា Jiang Ziya នៃភ្នំ Kunlun Yuanshi Tianzun ។

និទានចិនបានតំណាលថា បុរសនេះតែងតែអង្គុយឯកោស្ទូចត្រីដោយឥតដាក់ផ្លែសន្ទូចនិងនុយទេ។ អ្នកស្រុកជិតៗល្បីឆ្ងល់តគ្នា នឹងវិធីនេសាទចម្លែករបស់គាត់ថាធ្វើម្តេចបានត្រី?

ប្រសិនមានអ្នកណាសួរ  លោកតាបានឆ្លើយថា "អ្វីដែលខ្ញុំកំពុងនេសាទនោះ មិនមែនជាត្រីមួយក្បាលទេ ប៉ុន្តែជាស្តេចនិងមហាឧបាសិកាជាច្រើន។ មានតែអ្នកដែលចង់មកតាមសន្ទូចទេ ទើបខ្ញុំចាប់បាន"។

អ្នកប្រវត្តិសាស្រ្តបកស្រាយថា សម្តីលោកតា Jiang Ziya មានន័យថាគាត់កំពុងរង់ចាំអ្នកគ្រប់គ្រងដ៏ឈ្លាសវៃ ដែលទទួលស្គាល់ទេពកោសល្យរបស់គាត់ ហើយត្រូវការគាត់ជួយ។

គ្រានោះមានរាជវង្សមួយអង្គល្បីល្បាញខាងមានទសពិតរាជធម៌ គឺព្រះបិតុលាបង្កើតនៃស្តេចចូវព្រះនាមថា ប៊ី ហ្គាន Bi Gan។ ទ្រង់ល្បីថាជាមនុស្សមានបេះដូង៧ថត ចិត្តទូលាយនិងចិត្តល្អដូចព្រះ មានគេរ៉ឺឈ្មោះជាអ្នកប្រាជ្ញផងដែរ។

ពេលទ្រង់ខំស្កាត់រកលោកតាទូលពីបញ្ហារបស់ស្ដេចចូវលោកតាបានឱ្យទំនាយប្រាប់មុនថា

«Bi Gan អើយ អ្នកជាមនុស្សស្មោះត្រង់និងសប្បុរស! តែគិតអ្វីរឿងនៃស្ដេចចូវ? បើទ្រង់ខ្លួនឯងនឹងសោយទិវង្គតក្នុងពេលឆាប់ៗផង!»

ឮហើយព្រះបិតុលា Bi Gan ពិបាកចិត្តពេកក៏វិលមកវាំងវិញរកគាល់ស្ដេចចូវ នៅវេលាយប់ចំពេលក្លាយជាស្ដេចនេះមកប្រាប់អួតថា មានពិធីជប់លៀងដែលរៀបចំដោយ មាន "វិញ្ញាណអមតៈ" ជាច្រើននឹងលេចចេញមកឱ្យឃើញ។ ស្ដេចចូវហាក់មានសេចក្ដីសោមនស្សរីករាយដែលបានឃើញ "វិញ្ញាណអមតៈ" ទាំងនោះលេចចេញមក។ តាមពិត គឺពិតជាវិញ្ញាណកញ្ជ្រោងរបស់ Daji បង្កើតរូបភាពក្លែងបន្លំ ហើយព្រះបិតុលាBi Gan ដែលមានវត្តមាននៅក្នុងពិធីជប់លៀងនោះចាប់អារម្មណ៍ថា មានបិសាចមកពពាក់ពពូនបន្លំភ្នែកស្ដេច។

ដោយការសង្ស័យរបស់ខ្លួនបិតុលា Bi Gan ព្យាយាមតាមដាននិងធ្វើជាស្រវឹង។ គ្រប់យ៉ាងត្រូវបានបញ្ជាក់នៅពេលដែលវិញ្ញាណកញ្ជ្រោងស្រវឹងពេក បញ្ចេញកន្ទុយរបស់ពួកគេមកដោយមិនដឹងខ្លួន។

វិលមកវិញ ព្រះបិតុលា Bi Gan បានលបបញ្ជូនសារចេញប្រមូលផ្ដុំកោះហៅបានទាហានជំនិតមួយក្រុមមកភ្លាមឱ្យជួយតាមដានវិញ្ញាណកញ្ជ្រោងពេលពួកវាត្រឡប់ទៅរូងវិញ។

ពេលនោះហើយព្រះបិតុលា ហើយសម្លាប់ពួកវាទាំងអស់ពន្លាត់ស្បែក កញ្ជ្រោងដេរធ្វើអាវធំខៃរងាយកថ្វាយទៅស្ដេចចូវ និងកន្សែងបង់កសម្រាប់តាជី។

បានឃើញកាលណាតាជីរន្ធត់ចិត្ត និងសោកស្ដាយ លួចរៀបគម្រោងសងសឹកលើ Bi Gan ជាសម្ងាត់ ដោយឱ្យស្ដេចចូវកោះហៅព្រះបិតុលា មកសួរថាតើអាវល្អនេះបានមកពីណា។

បិតុលាបានស្ម័គ្រចូលទៅជួបគាល់ស្ដេចចូវដោយផ្ទាល់ ដើម្បីនិយាយពន្យល់សារជាថ្មីសព្វគ្រប់បែបយ៉ាង រាប់ពីមន្តសណ្ដំពួកញ្ជ្រោងមិនមែនជាអមតៈអ្វីទាំងអស់ នឹងស្នើឱ្យបញ្ជាដកហូតអំណាចទាំងអស់ពីស៊ូតាជី និងធ្វើទោសកុំឱ្យរាស្ត្រក្រោធខឹងខ្លាំងជាងនេះ។

គ្រានោះនៅពេលឃើញនាងកញ្ជ្រោងស៊ូតាជីក៏មកដល់ ព្រះបិតុលានៅបង្អង់ឆ្លើយប្រាប់លម្អិតទៀតថា ពួកកញ្ជ្រោងចង្រៃវាស្រវឹងទន់ ម្នាក់ៗស្លាប់មិនបានតដៃទេ ចំណែកទាហានយើងបានកាត់តម្រឹមយកកន្ទុយពួកវា មកធ្វើជាកន្សែងបង់ក ជូនអំណោយស្នំឯក និងពន្លាត់ស្បែកវាថ្វាយព្រះអង្គដណ្ដប់កាយ ដុតរូងវា មិនឱ្យវិញ្ញាណបានចេញទៅចាប់ជាតិឡើយ។

ស៊ូតាជី ឮហើយតក់ស្លុត និងចងគំនុំសឹងរំលំរាជវាំងនេះឲ្យបាន។ ខណៈព្រះបិតុលាយាត្រាចាចេញបាត់កាលណា នាងកញ្ជ្រោងបានពុតជាដួលសន្លប់នៅនឹងមុខបល្ល័ង្ក។

តមកក៏ធ្វើជាដេកឈឺល្វិតល្វៃនឹងគ្រែបាយមិនឆី ទឹកមិនផឹក ខ្សោះខ្លួន ស្គមកំប្រឹង។

ដោយស្តេចស្លន់ស្លោជាមួយរាជពេទ្យរកទំនុកព្យាបាលនាងមិនឃើញ នាងបានផ្តុំអាគមឱ្យរាជពេទ្យនិយាយបំផ្លើសថា ស៊ូតាជីនិងស្លាប់ក្នុងបីថ្ងៃ។

ពេលនោះស្តេចសោកសង្រេងជាខ្លាំងមិនទៅណាចោលគ្រែនាងឡើយ។

បានឱកាសតាជីបាននិយាយទៅកាន់ស្តេចថា នាងគាំងបេះដូងបណ្តើរៗ ហើយយើងនឹងលាគ្នាលែងបានជួបត្រឹមណេះ មានតែជាតិមុខនឹងផ្សងរួមមេត្រីប្តីប្រពន្ធទៀត។

ស្តេចមិនសុខចិត្តស្រែកឡើងថា ឱលោកនេះមានអ្វីកែវាសនាគម្រក់នេះចេញបាន?

"បេះដូងថតប្រាំពីរ! "

កញ្ជ្រោងឆ្លើយថា មានតែបេះដូងថត៧ប៉ុណ្ណោះដែលអាចបំបាត់ការឈឺចាប់និងពន្យារសេចក្តីស្លាប់ចេញពីខ្លួនរបស់នាងបាន។

ស្តេចចូវសួរឡើងដោយសោមនស្សថា ហេតុអ្វីយើងដូចធ្លាប់ឮពាក្យនេះ?

កញ្ជ្រោងតបថា គ្មាននរណាម្នាក់ក្នុងលោកមានវាឡើយ លើកលែងតែព្រះបិតុលាBi Gan ដែលត្រូវបានគេគោរពជាអ្នកបរិសុទ្ធ។

ការណ៍នេះបានលេចឮភ្លាមៗជាដំណឹងដល់ព្រះបិតុលា Bi Gan ឱ្យប្រុងប្រយ័ត្នខ្លួនបញ្ចេញឡើងដោយក្រុមមនុស្សល្អស្មោះត្រង់ក្នុងរាជវាំង។

ពេលព្រះបិតុលាខំស្កាត់ទៅរក លោកតា Jiang Ziya លោកតាថា បានដឹងជាមុនហើយអំពីភាពឃោរឃៅនិងគំនុំរបស់តាជីព្រមទាំងមារយាទកែលែងឡើងរបស់ស្តេចចូវ។ ព្រះបិតុលាបាន ទូលសុំសួររកវិធីដើម្បីសង្គ្រោះជីវិតខ្លួនឯងនិងនគរផងលោកតានោះប្រាប់ថា ប្រសិនបើថ្ងៃណាមួយ តាជីពិតជាអាចចេញបញ្ជាវះយកបេះដូងរបស់ទ្រង់ សូមឲ្យព្រះបិតុលានៅស្ងៀមនិងចាប់យកបេះដូង ទាញចេញពីទ្រូងខ្លួនឯងកុំឱ្យអ្នកណាធ្វើ ហើយថ្វាយវាទៅស្តេចកំណាចចុះ។ ព្រះបិតុលានិងមិនស្លាប់ឬស្រក់ឈាមមួយតំណក់នោះទេ។ ផ្ទុយទៅវិញ ឆាប់ចាកចេញចេញពីវាំង ហើយទៅផ្ទះដោយមិនមើលក្រោយ ព្យាយាមធ្វើដូចគ្មានអ្វីកើតឡើង នឹងអាចរស់

បានមានជីវិតតទៅមុខទៀត ប៉ុន្តែចាប់តាំងពីរាជវាំងរហូតដល់ផ្ទះ ហាមមិនឲ្យនិយាយស្តីនិងអ្នកណាទាំងអស់។ ជាមួយនោះលោកតាបានឱ្យព្រះបិតុលា ចងចាំទន្ទេញបាលីមួយឃ្លាជាប់ជានិច្ចដែរ។

បែកចេញពីលោកតា មកដល់ដំណាក់វិញកាលណា ក៏ឃើញស្រេចនូវ ក្រុមសេនាវាំងកំពុងរង់ចាំមកនាំខ្លួន។ ទៅដល់អង្គជំនុំ ស្តេចចូវបានយំអង្វរសុំបេះដូងមាខ្លួន សង្គ្រោះជីវិតស្រីស្អាត

មហាបុរសបានធ្វើតាមការប្រាប់មកនៃលោកទេវតា ហើយដកហូតបេះដូងដែលពិតជាមានថត៧ ប្រគល់ដល់ក្មួយជាព្រះរាជា នឹងពោលឡើងថា ៖

ទូលបង្គំប្រគល់ហើយ!

រួចសេចក្តីព្រះបិតុលាបានចាកចេញមកឡើងគ្រែស្នែង រូតរះវិលមកផ្ទះព្រោះបានប្រាប់បង្គាប់ទៅអ្នកបម្រើជាមនុស្រេចហើយ។

នៅចប់តាមផ្លូវ គ្មានការឈឺចាប់អ្វីទាំងអស់។

វិញ្ញាណពួកក្រុមកញ្ជ្រោងជាច្រើន បានចេញមកក្លែងជាមនុស្សធម្មតាប្រជៀតគ្នា ដើរស្រែកចេចចាច នៅតាមផ្លូវដែលគេសែងព្រះបិតុលាត្រឡប់មកផ្ទះវិញ។

ទ្រង់ជ្រាបពួកនោះជាកញ្ជ្រោងដែរ តែព្រះបិតុលាបានព្យាយាមធ្វើតាមសម្តីលោកតាប្រាប់មក មិនខ្វល់ស្តាប់អ្វីក្រៅតែពីទន្ទេញបាលីបន្តជីវិត។

ស្រាប់តែមានពពួកកញ្ជ្រោងបិសាច ជាច្រើនទៀតបានលេចមុខឡើងមកថែម ដោយក្លែងខ្លួនជារាស្ត្រសាមញ្ញ យំផង ស្រែកផង ក៏ទ្រង់នៅមិនរវល់តបឆ្លើយ។

លុះមកដល់ក្បែរផ្ទះទៅហើយ នៅក្រៅរបងបែរជាឃើញមានស្ត្រីចាស់ម្នាក់កំពុងពពាយនាយថា លក់ស្ពៃគ្មានដើមៗៗៗ។

ស្ត្រីក្រីក្រនិយាយបែបនេះដដែលជាដដែល រហូតដល់ព្រះបិតុលាមិនអស់ចិត្ត ភ្លេចគិតថាអង្គឯងនៅក្រៅរបងផ្ទះនៅឡើយ ក៏បើកវាំងននគ្រែស្នែងងាកចេញមកមើល ដោយថែមទាំងឆ្លោយសួរថា ហៃស្ត្រីម្នាក់នោះ! តើដាំស្ពៃអ្វីដែរគ្មានដើមអាចរស់បាន?

ពួកកញ្ជ្រោងឮពាក្យសួរនេះហើយ បានក្អាកក្អាយសើចជាសំឡេងសត្វចេញឡើងពីក្នុងរាងកាយស្ត្រីទុរគត។

ព្រះបិតុលាខ្ទប់ទ្រូងដែលចុកចាប់ដោយអំណាចគ្មានខ្យល់ដក។

សត្វកញ្ជ្រោងបាន និយាយចំអកឲ្យទ្រង់ថា៖

«ត្រូវហើយស្ដេគ្មានដើមម្ដេចបាន មនុស្សគ្មានបេះដូងម្ដេចនឹងរស់?»

គ្រាន់តែពួកវាថាចប់កាលណា ព្រះបិតុលាបានចាប់ផ្ដើមដួលប្រកាច់ស្លាប់ដោយត្រដរខ្យល់នៅក្នុងគ្រែស្នែង។

មរណភាពនៃព្រះបិតុលា បានបណ្ដោយឱ្យការស្អប់ខ្ពើមរបស់រាស្ត្រនគរទាំងមូល កាន់តែមានសន្ទឹកសន្ធោឡើង បីដូចជាធ្យូងថ្មដុតឆេះក្រហម ផ្ទុះខ្វាយរងើគរាលកម្ដោចពាសពេញ។

ចំពោះការបាត់បង់ និងការពលីយ៉ាងអយុត្តិធម៌នៃមហាបុរសបេះដូង៧ចតបានក្លាយជាកំណាព្យដំណៀលរាប់រយបទកុមារកុមារីចេះចាំស្ទាត់ទូទាំងនគរ។

មិនយូរប៉ុន្មានស្ដេចចូវបានលង់ទៅក្នុងការស្រវឹងខួប បោះបង់ចោលខ្លួនឯង។

នាងកញ្ជ្រោងមិនអាចរកបានអ្នកកំដរតណ្ហា ក៏បានកើតចិត្តឯកា ខំស្វះស្វែងរកបុរសណាម្នាក់សង្ហាផុតគេនឹងអាលបានមកជាកំដរតណ្ហានាងជំនួសស្ដេចចាស់ដែលវង្វេងសុរាព្រោះថ្កោលទោសខ្លួនឯងរឿងស្ដេចបិតុលាត្រូវសុគតរងដំណៀលពេញស្រុក។

ព្រឹកមួយនាងតាជី បាននឹកឃើញវិលមកលេងផ្ទះ។ ឪពុកនាងមិនបានស្វាគមន៍នាងទេព្រោះខ្ពើមស្អប់អ្វីដែលបានឮ។ ដូច្នេះនាងបានគុំទុក ដែលក្រោយមកមានការលើកឡើងថានាងបានបញ្ជាឱ្យគេឃុំបង្អត់ចំណីឪពុកខ្លួន ថែមទាំងធ្វើទណ្ឌកម្មផងដែរបើកុំតែបានបងស្រីនាងមកសុំអង្វរថា សូមទុកជីវិតពុក ជាជំនួនមង្គលការបងស្រីផង ទើបកញ្ជ្រោងយល់ព្រម។

ពេលនោះហើយ តាជី  ជំពើបឃើញកម្លោះអ្នកប្រាជ្ញម្នាក់ ឈ្មោះ Bo Yikao ជាកូនប្រុសច្បងរបស់មេទ័ព Ji Chang  បច្ចុប្បន្នជាស្ដេចត្រាញ់ភាគខាងត្បូងប្រទេស។ កម្លោះនេះត្រូវជាគូដណ្ដឹងបងស្រីនាង។ ដោយសារកម្លោះកូនរបស់ Ji Chang នេះមានកាយសម្បារឹងប៉ឹងនិងទឹកមុខសមដូចទេវតា វាចាពីរោះទន់ភ្លន់ នាងតាជីបានលង់ស្នេហ៍ជាពន្លឹក។

តាជី ពិតជាបានវិលមកវាជដំណាក់វិញ ទាំងនឹកស្រមៃដល់ប្រុសនេះមិនអស់មិនហើយព្រោះតែចិត្តស្នេហាក្ដៅរោលរាល។

Daji បាននឹកឃើញមធ្យោបាយទៅពង្វក់ស្ដេចចូវថា  Ji Chang ដែលជាអ្នកយាមនគរ

ស្តេចត្រាញ់ខាងត្បូងចង់ក្បត់ ត្រូវកោះហៅឱ្យមកស្ថិតនៅក្រោមការឃុំខ្លួនក្នុងផ្ទះជាហេតុឱ្យកូនប្រុសច្បងរបស់ Ji Chang គឺ Bo Yikao នេះឯង ស្រូតមករកអង្វរសុំការដោះលែងឪពុក។

កញ្ញ្រោងDaji ដែលធ្លាក់ក្នុងអន្លង់ស្នេហ៍ជាមួយ Bo Yikaoខ្លាំងបានបង្គាប់អនុញ្ញាតឱ្យ Bo Yikao បង្រៀននាងពីរបៀបលេងភ្លេង និងលុះដល់ទិវាមួយនាងបង្គាប់កុហកថា ស្តេចឱ្យប្រុសកម្លោះនោះចូលមកគាល់។ ឯទីដែលប្រុសនោះមកដល់ តាមពិតជាទីអាងទឹកនៃនាងកំពុងត្រាំខ្លួនយ៉ាងអាសអាភាសមិនសមរម្យ។ កញ្ញ្រោងបានប្រឹងបង្កើតទំនាក់ទំនងស្នេហាភេទជាមួយបុរសអភិជន តែជននេះមិនព្រមតបស្នង ថែមទាំងមានបុណ្យតាមការពារមិនឱ្យនាងផ្តុំស្នេហ៍ស្នូកបាន។

លុះអង្វរច្រើនយ៉ាងណាបានត្រឹមខាងប្រុសតិះដៀល កញ្ញ្រោងសត្វបានកើតចិត្តពិរោធឈឺចាប់ទៅជាស្អប់។ គាប់ចួនស្តេចចូវដើរមកដល់ដែរ ទើបនាងកញ្ញ្រោងបានឱកាសសម្លាប់ឱ្យផុតនឹក បំណាច់នឹងគង់មិនបាននៃបនិត្យ ក៏បន្លំស្រែកមួលបង្កាច់ថា ជាការចាប់ប្រលោមពីខាងប្រុស។

ស្តេចដែលលែងដឹងអ្វីជាអ្វីទៅហើយ បានដាក់បញ្ជាឱ្យចាប់ចង ចៅនេះយកទៅសម្លាប់ចោល។ ដោយហេតុគំនិតជួរជាតិ នាងតាជីបានចងអាឃាតរហូតបញ្ជាឱ្យហៅឪពុកគេនេះចូលមកដែរហើយបញ្ជាចុងភៅស្ងោរសាកសពរបស់យុវជននោះបញ្ជាឲ្យឪពុកលើកឆីចំពោះមុខស្តេច ពុំនោះទេនឹងត្រូវចោទថាក្បត់រាជដែរ។

មេទ័ពជូ ព្រោះតែអត់ធន់សងសឹកបានខំប្រឹងធ្វើតាមបញ្ជាយ៉ាងឈឺចាប់។ តាជីនិយាយថាកោតពួកមនុស្សដែលនិយាយកោកៗថា មានតែសត្វទេឆីកូនឯង ដូច្នេះពួកមនុស្សឯងនេះមិនស្មើសត្វនៅឡើយ។

មេទ័ពជូបានជេរប្រទេសនាងថា ជាអម្បូរសត្វកំណាចពុតត្បុតម្ល៉ោះហើយក៏ត្រូវទទួលការឃុំរង់ចាំប្រហារ។

ទោះបីយ៉ាងណាក្រុមបះបោរជាច្រើនបានព្យាយាមទម្លាយគុកស្វែងរករំដោះលែងមេទ័ពនេះចេញពីគុកវិញ។

ដប់បីឆ្នាំក្រោយឯណោះ គឺបន្ទាប់ពីការស្លាប់របស់កូនប្រុសពៅខ្លួន ឪពុករូបនេះបានបើកការវាយប្រហារប្រឆាំងនឹងរដ្ឋស្នាង ដើបប្រឆាំងនឹងស្តេចចូវស្រវឹងខួប ដើម្បីសងសឹកជូនគ្រួសារខ្លួនរហូតបានសម្រេចទាំងស្រុង។

ជ័យជម្នះនេះ កើតឡើងគួបផ្សំដោយសារកំហឹងនិងការស្អប់ខ្ពើមដែលលេចផុសឡើងកាន់តែខ្លាំងក្នុងជួររាស្រ្តនិងទ័ព ដោយសារតែភាពឃោរឃៅរបស់ស្តេចចូវនិងតាជី ដែលគេនិយមហៅថា កញ្ជ្រោងបិសាច។

ជាមួយនឹងមធ្យោបាយទប់ទល់ការបះបោររីករាលដាលទូទាំងនគរ ចុងក្រោយតាជីបានបង្កើតឡើងនូវទារុណកម្មកាន់តែព្រៃផ្សៃ ដូចជាការចាប់ចងមន្ត្រីឃោជាមួយនៅលើសសរដុតភ្លើងក្តៅ ឲ្យពួកគេរលាកស្លាប់បន្តិចម្តងៗ ដោយនាងអង្គុយពិនិត្យមើលឬសោយអាហារជាមួយស្តេចលេលា។

នៅក្នុងការគំរាមដល់គ្រួសារមន្ត្រីនៃនគរទាំងមូលមិនឲ្យហ៊ានក្បត់ជាមួយនឹងក្រុមខ្លួន ប៉ុន្តែការគ្រប់គ្រងបែបនេះបានបណ្តាលឱ្យតំបន់ជាច្រើនដែលមានមន្ត្រីបះបោរប្រឆាំង ប្រកបទៅដោយកម្លាំងនៃអំពើល្អនិងមានជំនឿមុតមាំទៅលើការផ្លាស់ប្តូរបានលើកទង់ដឹកនាំដោយមេទ័ពចូវសម្រុកវាយរុញរហូតរលាយរាជវាំងស្ហាង។

អ្នកប្រវត្តិសាស្រ្តបានសរសេរថា រាជវង្សត្រូវវិនាស ស្តេចចូវបានធ្វើអត្តឃាតដោយដុតខ្លួនឯង។ ចំណែកមេទ័ពជូ ជាឪពុកដែលត្រូវតាជីបង្ខំឱ្យឆីសាច់របស់កូនប្រុសខ្លួនឯង ក្រោយមកបានឡើងសោយរាជ្យបង្កើតរាជវង្សជូ។

តាជីបានរត់ទៅរកព្រះណូវ៉ាទាមទារជីវិតអមតៈដូចការនិយាយពីខាងដើម ប៉ុន្តែព្រះណូវ៉ាបានលើកឡើងថា សត្វកញ្ជ្រោងកំណាចកន្ទុយ៩ ជាសត្វមានពុត គ្មានឈាមគ្មានចិត្ត បានសម្លាប់មន្ត្រីល្អ និងមានវិធីឃោរឃៅ ម្តេចនឹងសមបានរស់នៅបន្តលើលោកនេះ ក្លាយទៅជាសត្វអមតៈអន្សាបាន?

ដូច្នេះបន្ទាប់ពីការដួលរលំទៅនៃរាជវង្សក្សត្រចូវភ្លាមៗ ព្រះម៉ែណូវ៉ា បានកាត់ទោសតាជីដែលជាសត្វកញ្ជ្រោងមួយក្បាលមានកន្ទុយដល់ទៅ៩ ឲ្យស្លាប់នៅនឹងមុខទ្រង់ ជំនួសឲ្យការប្រទានជីវិតអមតៈ។

ទោះបីយ៉ាងណា អ្នកប្រវត្តិសាស្រ្តបច្ចុប្បន្ននេះនៅប្រទេសចិនបានប្រកាសថា រឿងអំពើឃោរឃៅច្រើននៃរឿងព្រេងស្តេចចូវមិនពិតជាច្បាស់ទេ អាចជាការឃោសនា កាលពីសត្រូវចង់វាយលុកនគរ គឺបានពន្លើសនៅលើផ្នែកខ្លះជាមនោគវិជ្ជាយកទៅប្រឆាំងនឹងរាជវង្សស្ហាង និងរកប្រជាប្រិយភាពឱ្យក្រុមបះបោរនៃមេទព័ជូ។

អ្នកស្រាវជ្រាវបានអះអាងថា ការសរសេរកំណាព្យប្រឆាំង គឺពេញនិយមណាស់ក្នុងសង្គមចិនដើម្បីបង្អាប់ស្តេចណាម្នាក់ និងបានប្រមូលផ្តុំបានការគាំទ្រពីមជ្ឈដ្ឋានផ្សេងៗក្នុងបុព្វហេតុរំលំរាជ ប្តូរសម័យកាល។ ជាក់ស្តែងបណ្តាព័ត៌មានដែលបានផ្សព្វផ្សាយចេញ រៀបរាប់អំពីអំពើឃោរឃៅនៅក្នុងរាជវាំងនៃស្តេចចូវក្រោមគំនិតបញ្ចោរបស់តាជី ពិតជាអាចកេណ្ឌបានមកនូវកម្លាំងបះបោរទូទាំងប្រទេសរហូតដល់ទប់លែងរួចមែន។

អ្នកស្រាវជ្រាវ បានដាក់ស៊ូតាជីនិងស្តេចចូវថាក្លាយជាជនរងគ្រោះនៃសង្គ្រាមចិត្តសាស្ត្រ ធំដំបូងគេដែលប្រវត្តិសាស្ត្រចិនមិនធ្លាប់មាន បានន័យថាអ្នកទាំងពីរមិនបានធ្វើយ៉ាងដូច្នេះ ប៉ុន្តែត្រូវបានគេយកមកសរសេរបំភ្លៃ ផ្សព្វផ្សាយពេញប្រទេសចិនរហូតដល់ដួលរលំរាជវង្សស្ពាង។

មានឯកសារខ្លះទៀត បានសរសេរថាដោយសារខ្លួនឯងជាស្តេចដែលតែងតែឈ្នះសង្គ្រាម និងទទួលបានស្នេហារាប់ពាន់នាក់ដូចបំណងប្រាថ្នានូវរាល់ស្ត្រីស្អាត ទាំងក្រមុំនិងភរិយាគេ នៅតែស្តេចអធិរាជចូវមិនស្កប់ចិត្តវេលាយប់មួយ អធិរាជដែលបានឈ្លក់វង្វេងនឹងកាមគុណ សឹងថ្នាក់ឆ្កួតទៅហើយបានចូលទាំងស្រវឹងទៅ ក្នុងព្រះវិហារបរិសុទ្ធមួយរបស់ព្រះម៉ែណ្ហូវ៉ា ហើយបានបង្ហាញពីសេចក្តីស្រឡាញ់ដែលមិនទាន់បានសម្រេចមួយ គឺការចង់រួមរស់មេត្រីនឹងព្រះម៉ែណ្ហូវ៉ា។

ស្តេចចូវបាន ថ្វាយបង្គំព្រះនាងហើយសង្កេតនិងស្ទាបលើរូបសំណាកព្រះនាងរបៀបគិតថាមានភាពទាក់ទាញខ្លាំងណាស់។ ស្តេចល្ងីល្ងើបាននិយាយប្រមាថមើលងាយនៅមុខរូបសំណាកថា ឱ! ប្រសិនបើខ្ញុំអាចរៀបការជាមួយអ្នក។ ស្តេចចូវ ថែមទាំងបានសរសេរកំណាព្យនៅលើជញ្ជាំងថ្វាយបង្ហាញពីចំណង់តណ្ហារបស់ខ្លួនចំពោះព្រះនាងដែរ។

ភាពសៅហ្មងនៃកំហុសដ៏ធំនេះ មិនអាចគ្មានទណ្ឌកម្មឆ្លើយតបបានទេ។ ព្រះម៉ែណ្ហូវ៉ាបានដាក់បណ្តាសាថា ស្តេចនេះជាស្តេចចុងក្រោយនៃរាជវង្សចូវ។ ព្រះម៉ែណ្ហូវ៉ាបានកោះហៅវិញ្ញាណកញ្ជ្រោងដ៏អាក្រក់បំផុតមួយមានកន្ទុយ៩ និងមានជីវិតពាន់ឆ្នាំ ដោយដាក់ជាវិញ្ញាសារថា ទ្រង់នឹងពន្យល់សប្តិប្រដៅឱ្យព្រះចៅភ្ញាក់ខ្លួនពីរឿងតណ្ហាវិញ តែប្រសិនបើ ព្រះចៅអធិរាជចូវព្រមលង់លើកញ្ជ្រោង ដោយមានចេតនាបញ្ជោះជីវិតកខ្វក់កាមគុណនេះមិនឈប់

សូមបណ្តាលឱ្យរាជបល្ល័ង្កវិនាស។

អស់រយៈពេលរាប់ពាន់ឆ្នាំហើយ ដែលវិញ្ញាណកញ្ជ្រោងកន្ទុយប្រាំបួនបានរស់នៅ ដោយស្រងេះស្រងោចឈឺចាប់នឹងជំងឺម្យ៉ាងដែលមិនចូលចិត្តភាពស្អាត ចង់ឃើញតែភាពឈឺចាប់របស់អ្នកដទៃទើបអាចបំបាត់ការឈឺចាប់ខ្លួនឯងបាន។

ទីបំផុតពេលបានលេចចូលក្នុងទម្រង់ខ្លួនមនុស្ស កញ្ជ្រោងបានសន្មត់ថា ស៊ូតាជីមិនអាចប្រកែកនឹងវាសនានេះបានមិនមែនកំហុសខ្លួនឡើយ ហើយចំពោះអធិរាជចូវ ប្រសិនមិនល្មោភលង់ស្នេហ៍នាង ក៏នាងមិនអាចធ្វើអ្វីខុសបានលើនគរនេះដែរឡើយ។

ជាមួយនឹងកំពូលអំណាច អាចគ្រប់គ្រងដោយសេរីលើចក្រភព និងប្រជាជនរបស់ស្តេចចូវ ហើយនាងកញ្ជ្រោង Da Ji បានរើសយកការធ្វើទារុណកម្ម និងការព្យាបាទជាអាហារផ្លូវចិត្ត។ នាងត្រេកអរនឹងឮសម្រែកឈឺចាប់របស់គេហើយ ពេលនាងរាំ នាងបញ្ជាឱ្យលេងភ្លេងដែលផ្សំឡើងតាមបែបឃោរឃៅរំញ័រគ្រប់បទ។ អំពើឃោរឃៅបង្កឱ្យមានសោកសៅខ្លាំងនេះហើយ ដែលប្រជាជនបានក្រោកឡើងផ្តួលរំលំអ្នកគ្រប់គ្រង។ ពួកគេបានវាយលុកទ្វារ ផ្តួលរំលំរាជបល្ល័ង្ក ហើយដេញតាមសម្លាប់ស្តេចចូវដល់ដំណាក់ផ្ទំក៏ជាកន្លែងដែលអធិរាជដ៏ឆ្កួតលីលាបានចំណាយជីវិតយ៉ាងអសីលធម៌។ ប៉ុន្តែ Da Ji បានរត់គេចខ្លួន និងលាក់ខ្លួននារូងជ្រៅមួយ។

កញ្ជ្រោងតាជី ត្រូវបានគេចាត់ទុកនិងចងចាំថាជាអរូបដែល មិនមែនជាអាទិទេពតែមានចរិតដ៏ឃោរឃៅបំផុតក្នុងពិភពលោក។

បើសម័យនេះវិញ គេហៅបានថាជាក្រុមមនុស្សវិកលចរិកកម្រិតអាក្រក់បំផុត ដែលយកចិត្តទុកដាក់តែទ្រព្យសម្បត្តិ និងការលួងលោមខណៈចិត្តខ្លួនឯងកម្សត់ឯកោ កើតមកស្រលាញ់សង្គ្រាម និងចង់ឃើញសេចក្តីស្លាប់អ្នកដទៃ ដោយគ្រាន់តែសប្បាយភ្នែកលេង។

មានគេសរសេរទៀតថា នាងងើបឡើងរាំលេងបានខណៈកំពុងឮសំឡេងស្រែកនៃមនុស្សត្រូវបានគេធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។

តាជីនេះដែរ ត្រូវបានរៀបរាប់លម្អិតនៅក្នុងប្រលោមលោកស្នេហាបុរាណដ៏ល្បីរបស់ចិត្ត Fengshen Yanyi 封神演義សរសេរឡើងនៅសតវត្សទី១៦ និងជាស្នាដៃនិពន្ធរបស់ជនជាតិចិនដ៏ល្បីមួយរូបផ្នែករឿងប្រភេទព្រះនិងអារក្ស គឺចងក្រងសរសេរឡើងក្នុងរាជវង្សមីង (1368-1644) ចែកចេញជា១០០ជំពូក និងត្រូវបានបោះពុម្ពជាលើកដំបូងនៅក្នុងទម្រង់សៀវភៅវាងឆ្នាំ 1567 និង 1619។ សៀវភៅរឿងភាគនេះបញ្ចូលគ្នានូវធាតុផ្សំ

នៃប្រវត្តិសាស្ត្រ ព្រេងនិទាន ទេវកថា ជាមួយគ្នាក្នុងយុគសម័យនៃការធ្លាក់ចុះរបស់រាជវង្ស Shang (1600-1046 មុនគ.ស) និងការងើបឡើងនៃរាជវង្ស Zhou (1046-256 មុនគ.ស) ដែលមានភ្ជាប់ធាតុជាច្រើននៃទេវកថាចិន រួមទាំងអាទិទេព អមតៈ និងវិញ្ញាណ។ ស្នាដៃនិពន្ធនេះត្រូវបានសន្មតថាជារបស់ម្ចាស់ពិតគឺលោក Xu Zhonglin ។

ក្នុងប្រលោមលោកនេះ តាជីបានធ្វើបាបប្រពន្ធដើមរបស់ស្តេច Zhou នៃរាជវង្ស Shang និងបានជិះជាន់មន្ត្រីនានា បៀតបៀនអ្នកដែលស្អាត ល្បី រួមទាំងអ្នកដែលហ៊ាននិយាយរកនាងដែរ។

សម្រាប់ស្តេចត្រាញ់ខាងត្បូង Ji Chang ក៏ត្រូវបានកំណត់ត្រាមកថា មានម្តងបានស្កាត់រកជួបលោកតាJiang Ziya ឱ្យគន់គូរដែរ។ លោកតា Jiang Ziya ប្រាប់វិញថា អ្នកជាស្តេចនៅពេលបន្តិចទៀតនេះ ហើយអាណាចក្រ (រាជវង្សអ្នក) នឹងមានកាលវេលាបានរហូតដល់ ៨០០ ឆ្នាំ។ ប៉ុន្តែកូនប្រុសច្បងអ្នក នឹងជិតលាទៅមិនខានព្រោះស៊ូតាជី។ Ji Chang ចង់សុំជំនួយតែលោកតាបានរាដៃហើយប្រាប់ទៀតថា វាជាវាសនា ចំណែកខ្លួនឯង បើមានអ្នកណាយកអ្វីឱ្យហូបប្រាប់ថាជាសាច់កូនប្រុស អាចគិតថាគ្មានរឿងបែបនេះទេ លោកនេះទទេ ចាននោះក៏មិនមានសាច់ដែរ។

ចប់